# លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្ម
# ថ្នាក់ឯកជនពិសេស/ថ្នាក់ស្វ័យសិក្សា

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះរួមបញ្ចូលដោយភាគីរបស់វិទ្យាស្ថានបារាំងដែលមានទីតាំងនៅភ្នំពេញ(កម្ពុជា)មានឈ្មោះថា"**IFC**" និងភាគីម្ខាងទៀតគឺជាអ្នកដែលចង់ប្រើប្រាស់សេវាកម្មរបស់វិទ្យាស្ថានបារាំងមានឈ្មោះថា "**អតិថិជន** "។

## កម្មវត្ថុ

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះមានគោលបំណងកំណត់នូវកិច្ចសន្យារវាងវិទ្យាស្ថានបារាំងជាមួយអតិថិជននិងលក្ខខណ្ឌអនុវត្តចំពោះគ្រប់ការទិញឬប្រើប្រាស់សេវាកម្មរបស់វិទ្យាស្ថានបារាំងដែលអតិថិជនប្រើប្រាស់សំរាប់ការងារអាជីពឬការងារឯកជន។
ក្រុមការងាររបស់វិទ្យាស្ថានបារាំងផ្តល់សេវាកម្មគ្រប់បណ្តាញខ្លួននៅទូទាំងប្រទេស។
ការទទួលបានសេវាកម្មណាមួយពីវិទ្យាស្ថានបារាំងតម្រូវឱ្យអតិថិជនទទួលយកទាំងស្រុងនូវលក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះ។
លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះគ្របដណ្តប់លើលក្ខខណ្ឌទូទៅដ៏ទៃទៀតឬលក្ខខណ្ឌដោយឡែកដែលមិនបានបង្ហាញតែបានទទួលស្គាល់ជាផ្លូវការដោយវិទ្យាស្ថានបារាំងនៅកម្ពុជា។
វិទ្យាស្ថានបារាំងនៅកម្ពុជារក្សាសិទ្ធកែប្រែលក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មរបស់ខ្លួនបានគ្រប់ពេល។ ក្នុងករណីនេះអតិថិជននឹងចុះហត្ថលេខាជាថ្មីនៅពេលចុះឈ្មោះម្តងទៀត។
តម្លៃសេវាកម្មគ្រប់ផ្នែកដែលមានចែងក្នុងលក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះជាតម្លៃដែលគិតជាដុល្លារអាមេរិកាំងនៅលើគេហទំព័រ។

## មាត្រា១ : និតិវិធីនិងលក្ខខណ្ឌទូទៅក្នុងការប្រើប្រាស់សេវាកម្មថ្នាក់ឯកជនពិសេស

### ក ការចុះឈ្មោះ

### ១ ការចុះឈ្មោះអនឡាញ

A. អតិថិជនអាចចុះឈ្មោះតាមគេហទំព័ររបស់យើងបានដោយចូលទៅកាន់ទំព័រថ្នាក់ឯកជនពិសេស។
B. នៅលើទំព័រនោះ អ្នកគ្រាន់តែបំពេញពាក្យអនឡាញនោះជាមួយពិតមានចាំបាច់ ដូចជាគោត្តនាម នាម លេខទំនាក់ទំនង កម្រិតដែលចង់បាន ម៉ោងដែលចង់រៀន។ល។
C. នៅពេលបំពេញពាក្យរួចរាល់ហើយ ក្រុមការងាររបស់យើងនឹងទាក់ទងទៅអ្នកដើម្បីសាកសួរពិតមានបន្ថែមពាក់ព័ន្ធនឹកថ្នាក់ ម៉ោងនិងឆ្លើយសំណួរផ្សេងៗរបស់អ្នក។
D. ការទូទាត់ថ្លៃសិក្សាអាចធ្វើពីចម្ងាយបន្ទាប់ពីអ្នកទទួលបានវិក័យបត្រតាមអ៊ីមែលតាមរយៈQR Code។
E. បន្ទាប់ពីបានទទួលប្រាក់ហើយ អ្នកនឹងទទួលបានអ៊ីមែលដើម្បីបញ្ជាក់ពីការចុះឈ្មោះនឹងទទួលបានពិតមានចាំបាច់សម្រាប់ចាប់ផ្តើមរៀន។

RÉPUBLIQUE FRANÇAISE
*Liberté Égalité Fraternité*

INSTITUT FRANÇAIS — Liberté Créativité Diversité

## ២ ការចុះឈ្មោះដោយផ្ទាល់

A. អតិថិជនអាចមកចុះឈ្មោះនៅទីតាំងផ្ទាល់បានដែរ។ ក្រុមការងារយើងខ្ញុំនឹងទទួលអ្នកដើម្បីផ្ដល់ព័ត៌មានពិស្តារពាក់ព័ន្ធនិងថ្នាក់ឯកជនពិសេសហើយនិងឆ្លើយរាល់សំណួររបស់អ្នកផងដែរ។
B. អ្នកអាចបំពេញពាក្យចុះឈ្មោះជាក្រដាសនៅនិងកន្លែង ដោយបញ្ជាក់ពីតម្រូវការនិងក្ដីរំពឹងរបស់អ្នកក្នុងការរៀននេះ (កម្រិត រៀនប៉ុន្មានថ្ងៃ រៀនម៉ោងណា។ល។)។
C. ការបង់ថ្លៃអាចធ្វើបាននៅនិងកន្លែងតាមរយៈQR Code តាមកាតធនាគារ តាមការផ្ទេរប្រាក់ឬក៏ទៅបង់លុយសុទ្ធនៅសាខាធនាការ BRED តាមគណនីយដុល្លារ។
D. បន្ទាប់ពីបង់ថ្លៃរួច អ្នកនឹងទទួលបានបង្កាន់ដៃរួមទាំងកាលវិភាគសិក្សា។

**ក្នុងករណីទាំងពីរ** ក្រុមការងារនឹងនៅជួយសម្រួលនិងនាំផ្លូវអ្នកក្នុងការចុះឈ្មោះ។

វិទ្យាស្ថានតំរូវអោយធ្វើតេស្តវាស់ស្ទង់កំរិតភាសាសំរាប់អតិថិជនដែលធ្លាប់រៀននៅក្រៅវិទ្យាស្ថាន ឬនៅវិទ្យាស្ថានប៉ុន្តែបានផ្អាកការសិក្សាចាប់ពី២វគ្គជាប់ៗគ្នាឡើងទៅ។ ការធ្វើតេស្តវាស់ស្ទង់កំរិតមិនតម្រូវឲ្យបង់ថ្លៃទេហើយធ្វើតាមអនឡាញ។

បន្ទាប់ពីចុះឈ្មោះហើយភ្លាម អតិថិជននឹងទទួលបានគណនីយសិស្ស (Student Portal) ឯកជនមួយភ្លាមដែលនៅទីនោះអតិថិជនអាចដឹងព័ត៌មានទាក់ទងនឹងការសិក្សា ការទូទាត់ថ្លៃសិក្សារួមទាំងប្រវត្តិការសិក្សារបស់គាត់ (មេរៀន ការងារធ្វើនៅផ្ទះនិងលិខិតបញ្ជាក់ការសិក្សាដែរ)។

## ខ បែបបទនៃថ្នាក់ឯកជនពិសេស

ថ្នាក់ឯកជនពិសេសគិតជាកញ្ចប់១០ម៉ោងឬ៤០ម៉ោង។ ការទិញមួយម៉ោងៗគឺមិនអាចបានទេ។ ចំពោះថ្នាក់ឯកជនសម្រាប់មនុស្សច្រើននាក់ សូមសរសេរមក៖ infocours@ifcambodge.com

1. កញ្ចប់១០ម៉ោងនៃថ្នាក់ឯកជនពិសេសគឺមានសុពលភាពត្រឹម៣ខែ គិតចាប់ពីថ្ងៃចុះឈ្មោះហើយ។
2. កញ្ចប់៤០ម៉ោងនៃថ្នាក់ឯកជនពិសេសគឺមានសុពលភាពត្រឹម៨ខែ គិតចាប់ពីថ្ងៃចុះឈ្មោះហើយ។
3. ហួសរយៈពេលនេះ ម៉ោងដែលមិនបានរៀនមិនអាចសុំលើកឬសុំដកប្រាក់វិញបានទេ។
4. មួយកញ្ចប់ប្រើសម្រាប់តែអ្នករៀនម្នាក់គត់។
5. ថ្នាក់ឯកជនពិសេសដែលរៀនតាមអនឡាញឬក៏រៀនផ្ទាល់នៅវិទ្យាស្ថាន គឺមានតម្លៃដូចគ្នា។
6. ថ្នាក់ឯកជនពិសេសដែលរៀននៅក្រៅវិទ្យាស្ថានគិតតម្លៃពិសេសដោយបូកបញ្ចូលថ្លៃធ្វើដំណើរ។

## គ បែបបទនៃថ្នាក់ស្វ័យសិក្សា

ថ្នាក់ស្វ័យសិក្សាមានបញ្ចូលស្វ័យសិក្សារបស់សិស្សតាមរយៈវិបសាយe-learning ដែលផ្ដល់ដោយវិទ្យាស្ថាន និងការរៀនជាមួយគ្រូណែនាំដែលមានបទពិសោធន៍ដោយផ្ទាល់ឬតាមអនឡាញ។

1. សិស្សត្រូវបានចុះឈ្មោះទៅក្នុងកម្មវិធីស្វ័យសិក្សា
2. ចំនួនម៉ោងសិក្សាជាមួយគ្រូណែនាំប្រែប្រួលទៅតាមកញ្ចប់ដែលសិស្សជ្រើសរើសពេលចុះឈ្មោះ។
3. ម៉ោងសិក្សាជាមួយគ្រូណែនាំមានសុពលភាពត្រឹម១៥សប្ដាហ៍គិតចាប់ពីថ្ងៃចុះឈ្មោះ។
4. ហួសកាលកំណត់នេះ សិស្សមិនអាចសុំសងប្រាក់សម្រាប់ម៉ោងដែលមិនបានរៀននោះទេ។

5. កាលវិភាគជាមួយគ្រូណែនាំត្រូវបានកំណត់នៅពេលចុះឈ្មោះ។ សិស្សអាចសុំលើកថ្ងៃរៀនបានតែត្រូវផ្តល់ដំណឹងមុនយ៉ាងតិច២៤ម៉ោង បើពុំនោះទេគឺចាត់ទុកដូចជាបានរៀនដែរ។
6. ថ្នាក់មួយសម្រាប់តែសិស្សម្នាក់គត់។
7. អាសយដ្ឋានភ្ជាប់ទៅវិបសាយe-learningនឹងផ្ញើទៅសិស្សបន្ទាប់ពីចុះឈ្មោះហើយ។
8. សិស្សត្រូវប្រាកដថាមានសេវាអ៊ីនធើណេតល្អនិងឧបករណ៍ប្រើប្រាស់ចាំបាច់គ្រប់គ្រាន់សម្រាប់រៀន។

## មាត្រា២ - តំលៃនិងបែបបទបង់ប្រាក់នៃថ្នាក់ឯកជនពិសេស

### ក បែបបទនៃការបង់ប្រាក់

អតិថិជនត្រូវទូទាត់ថ្លៃសិក្សាយ៉ាងតិច៤៨ម៉ោងមុនថ្ងៃចូលរៀន។ ការបង់ថ្លៃអាចធ្វើបានតាមរយៈការផ្ទេរប្រាក់តាមធនាគារ(ទៅកាន់ធនាគារក្នុងស្រុកឬនៅបារាំង) តាមកាតធនាគារ តាមការផ្ទេរប្រាក់ឬក៏ទៅបង់លុយសុទ្ធនៅសាខាធនាការBREDតាមគណនីយដុល្លារ។

### ខ សៀវភៅមេរៀន

1. គ្រូនឹងប្រាប់ថាតើសិស្សចាំបាច់ត្រូវទិញសៀវភៅដោយសារវាអាស្រ័យលើកម្មវិធីសិក្សាដែលធ្វើឡើងទៅតាមគោលដៅដែលបានកំណត់ដោយអតិថិជន។
2. វិទ្យាស្ថានមិនអនុញ្ញាតិឱ្យប្រើសៀវភៅថតចម្លងទេ។ អតិថិនសន្យាថាមិនប្រើសៀវភៅថតចម្លងនៅក្នុងថ្នាក់ទេ។ វិទ្យាស្ថានរក្សាសិទ្ធិមិនទទួលអតិថិជនដែលគ្មានសៀវភៅច្បាប់ដើម លើកលែងតែឯកសារចម្លងដែលផ្តល់ដោយវិទ្យាស្ថាន។
3. សំរាប់ថ្នាក់ « Mon cours en ligne » និង« Ma Prépa DELF »ឯកសារផ្តល់ជូនតាមរយៈផ្លាតហ្វមវិទ្យាស្ថាន។

### គ ការសងប្រាក់ឬការសុំព្យួរ

ការចុះឈ្មោះចាត់ទុកថាជាផ្លូវការបន្ទាប់ពីបានទូទាត់ថ្លៃសិក្សានិងបានឯកភាពលើឯកសារនេះរួច។
អតិថិជនត្រូវតែបំពេញពាក្យសុំដកប្រាក់ដោយភ្ជាប់ជាមួយនូវឯកសារបញ្ជាក់មូលហេតុច្បាស់លាស់រួចយកពាក្យនោះមកដាក់នៅផ្នែកទទួលចុះឈ្មោះចូលរៀន ឬផ្ញើមកអាស័យដ្ឋានអ៊ីម៉ែល
infoscours@ifcambodge.com យោងទៅតាមលក្ខខណ្ឌដូចខាងក្រោម។

1. ករណីវិទ្យាស្ថានបិទថ្នាក់ ថ្លៃសិក្សាត្រូវបានតម្កល់ជាស្វ័យប្រវត្តិសម្រាប់អតិថិជនដែលមានសុពលភាពសម្រាប់មួយឆ្នាំ ដោយមិនគិតថ្លៃសេវាកម្មឡើយ។ តែបើអតិថិជនចង់ដកប្រាក់វិញអតិថិជនត្រូវតែបំពេញពាក្យសុំដកប្រាក់។
2. ករណីប្រធានសក្តិ (មានជំងឺធ្ងន់ធ្ងរ បាត់បង់ការងារ គ្រោះធម្មជាតិ មរណភាព ការចូលសំរាកពេទ្យ ការចាកចេញពីកម្ពុជាជារៀងរហូត) ថ្លៃសិក្សាត្រូវបានតម្កល់ជាស្វ័យប្រវត្តិ ហើយមានសុពលភាពមួយឆ្នាំដោយមិនពិន័យថ្លៃសេវាកម្មឡើយ។ បើអតិថិជនចង់ដកប្រាក់វិញ ត្រូវតែបំពេញពាក្យសុំដកប្រាក់។
3. រាល់ការលុបថ្ងៃរៀនណាមួយដោយអតិថិជន ត្រូវតែផ្តល់ដំណឹង២៤ម៉ោងមុន។ ការលើកថ្ងៃរៀនត្រូវអាស្រ័យលើភាពទំនេររបស់គ្រូ និងបន្ទប់រៀន។

### ឃ ការបញ្ចុះតំលៃ

1. បញ្ចុះតំលៃ២០%ពេលសិស្សយកកញ្ចប់៤០ម៉ោងចំពោះឯកជនពិសេស។ ការបញ្ចុះតម្លៃនេះមិនអនុវត្តចំពោះថ្នាក់ « Mon cours en ligne » និង « Ma prépa DELF »នោះទេ។
2. បញ្ចុះតម្លៃ១៥%នៅពេលអតិថិជនចុះឈ្មោះប្រលងសញ្ញាបត្រDELF/DALFប្រសិនបើអតិថិជនកំពុងរៀននៅពេលចុះឈ្មោះប្រលង។

### ង បណ្ណាល័យ

ក្នុងក្របខ័ណ្ឌចុះឈ្មោះនេះដែរអតិថិជនមានលទ្ធភាពប្រើប្រាស់សេវាកម្មបណ្ណាល័យពហុឯកសារដោយឥតគិតថ្លៃ (ខ្ចីឯកសារ និងមានសិទ្ធិចូលទៅកាន់បណ្ណាល័យអនឡាញ Culturethèque ថែមទៀតផង)។ សិស្សនិស្សិតត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់បណ្ណាល័យដែលចែងនៅលើ https://www.ifcambodge.com/fr/mediatheque/

## មាត្រា៣ - កម្មសិទ្ធិបញ្ញា

ម៉ាក ឈ្មោះវិស័យ ផលិតផល កម្មវិធីកុំព្យូទ័រ រូបភាព វីដេអូ អត្ថបទ ឬគ្រប់ព័ត៌មាន គ្រប់ឯកសារទាំងអស់សុទ្ធសឹងជាកម្មសិទ្ធិបញ្ញាផ្តាច់មុខរបស់វិទ្យាស្ថានបារាំងតែមួយប៉ុណ្ណោះ។ រាល់ការចំលង ការកែប្រែ ការប្រើប្រាស់ ផ្នែកណាក៏ដោយដើម្បីហេតុផលអ្វីក៏ដោយ ត្រូវបានហាមឃាត់ជាដាច់ខាត។

ក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវសេវាអេឡិចត្រូនិចនៃសារព័ត៌មាននៅវិទ្យាស្ថានដែលបានផ្តល់ជូនអតិថិជនគ្មាននរណាម្នាក់មានសិទ្ធិយកទៅបង្កើតថ្មីធ្វើអាជីវកម្មផ្សព្វផ្សាយឬផ្សាយបន្តទោះជាមួយផ្នែកណាក៏ដោយនូវរាល់ឯកសារដូចជាកម្មវិធីកុំព្យូទ័រឬរូបភាពឬឯកសារសំលេងដែលវិទ្យាស្ថានបានដាក់ឱ្យប្រើប្រាស់។

## មាត្រា៤ - ច្បាប់ថតរូបនិងទិន្នន័យផ្ទាល់ខ្លួន

វិទ្យាស្ថានរក្សាសិទ្ធិសុំព័ត៌មានពីអតិថិជន។ តាមរយៈការឯកភាពលើឯកសារនេះ អតិថិជនអនុញ្ញាត្តិឲ្យវិទ្យាស្ថាន៖

1. ប្រើប្រាស់ទិន្នន័យអតិថិជន ធានាការផ្តល់សេវាកម្ម ។
2. អនុញ្ញាត្តិឲ្យវិទ្យាស្ថានផ្តល់ទិន្នន័យពេលអ្នកចុះឈ្មោះទៅធនាគារដៃគូABA ដោយរក្សាការសម្ងាត់ ធដើម្បីឲ្យ ផ្ទេរប្រាក់តាមទូរស័ព្ទដៃ។
3. អនុញ្ញាត្តិឱ្យវិទ្យាស្ថានប្រើប្រាស់រូបភាពរបស់ខ្លួននៅតាមគេហទំព័រនិងតាមឯកសារផ្សព្វផ្សាយរបស់វិទ្យាស្ថានក្នុងក្របខ័ណ្ឌគរុកោសល្យតែប៉ុណ្ណោះ។ អតិថិជនមានសិទ្ធិចូលមើលនិងកែប្រែទិន្នន័យរបស់ខ្លួនផងដែរ។

## មាត្រា៥ - ករណីជម្លោះ

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាត្រូវចំណុះក្រោមច្បាប់ក្នុងស្រុកនៃប្រទេសកម្ពុជា។
ក្នុងករណីមានជម្លោះណាមួយ គូវិវាទត្រូវដោះស្រាយចំពោះមុខតុលាការក្នុងស្រុក។